# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010
## និង
## របាយការណ៍របស់សវនករឯករាជ្យ

# ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមហ៊ុន | **ធនាគារភ្នំមិ (ខេមបូឌា) អិលធីឌី** |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | Co. 1413/02E |
| ទីស្នាក់ការ | ផ្ទះលេខ ៩៤ ផ្លូវ ៣៦០<br>សង្កាត់ បឹងកេងកង៣ ខណ្ឌ ចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ម្ចាស់ភាគហ៊ុន | DWM Funds S.C.A.-SICAV SIF<br>TPC-ESPOP Co., Ltd. |
| ក្រុមប្រឹក្សាភិបាល | លោក Michael John Spingler ប្រធាន<br>លោកស្រី Fernanda Pecanha Lacerda De Lima<br>លោក Ry Vanna (លាលែងនៅថ្ងៃទី 10 ខែ មេសា ឆ្នាំ 2011)<br>លោក Chandula P.Abeywickrema (តែងតាំងនៅថ្ងៃទី17 ខែកញ្ញា ឆ្នាំ 2010) |
| គណៈនាយក | លោក Michael John Spingler នាយកប្រតិបត្តិស្តីទី<br>(តែងតាំងនៅថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 2011)<br>លោក ជួន សុផល នាយកប្រតិបត្តិ (លាលែងនៅថ្ងៃទី 31 ខែ មករា ឆ្នាំ 2011)<br>លោក សុខ រឿន ប្រធានប្រតិបត្តិការ (តែងតាំងនៅថ្ងៃទី19 ខែ មេសា ឆ្នាំ 2010)<br>លោក សុខ សុផល ប្រធានប្រតិបត្តិហិរញ្ញវត្ថុ(តែងតាំងនៅថ្ងៃទី2 ខែសីហា ឆ្នាំ 2010) |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ |

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1 | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| 2 | របាយការណ៍របស់សវនករឯករាជ្យ | 5 |
| 3 | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 7 |
| 4 | របាយការណ៍លទ្ធផលរួម | 8 |
| 5 | របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន | 9 |
| 6 | របាយការណ៍ចលនាសាច់ប្រាក់ | 10 |
| 7 | កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 12 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល **ធនាគារភូមិ (ខេមបូឌា) អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន") មានកិត្តិយសសូមដាក់ជូនពិនិត្យនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 ។

## សកម្មភាពចំបង

សកម្មភាពចំបងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដល់ប្រជាជននៅជនបទនៃប្រទេសកម្ពុជា តាមរយៈទីស្នាក់ការកណ្តាលនៅភ្នំពេញ និងទីស្នាក់ការនាបណ្តាខេត្តនានានៅក្នុងប្រទេសកម្ពុជា ។

គោលដៅរបស់ក្រុមហ៊ុន គឺត្រូវផ្តល់នូវសេវាមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងអាចលៃលកបានដល់សហគ្រិនខ្នាតតូចនៅតាមជនបទ និងបរិវេណជុំវិញទីក្រុងភ្នំពេញ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 មានដូចខាងក្រោម:

| | ពាន់រៀល |
|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | 4,396,294 |
| ពន្ធលើប្រាក់ចំណេញ | (906,427) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 3,489,867 |

## ទុនបំរុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបំរុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលហេនមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅ នឹងការលុបបំបាត់ចោល ឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោលហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឲ្យ ចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬ ចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កម្រិតសារវន្តណាមួយនោះទេ ។

E-mail : tpcho@tpc.com.kh
Tel : (855) 23 220 641 - Fax : (855) 23 220 642
#94, Street 360, Sangkat Boeung Keng Kang III,
Khan Chamkarmon, Phnom Penh, Cambodia

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ដែល បានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលមានតម្លៃមិនអាចលក់បាននៅក្នុង ប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ នោះទេ ។

## វិធីសាស្ត្រវាយតម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងទ្រព្យអកម្មផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន:

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ត្រូវបានធ្វើឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ ដើម្បីធានាបំណុលរបស់បុគ្គលណាមួយឡើយ និង

(ខ) បំណុលយថាហេតុណាមួយ កើតមានឡើងចំពោះក្រុមហ៊ុនចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែ បន្ទាប់ពីថ្ងៃបញ្ចប់នៃការិយបរិច្ឆេទ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬ អាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែក នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខ នៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជា សារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានយោបល់ផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ព្រឹត្តការណ៍ចាប់តាំងពីថ្ងៃធ្វើរបាយការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍សំខាន់ៗកើតមានឡើងនៅក្រោយថ្ងៃធ្វើរបាយការណ៍ដែលតម្រូវឲ្យមានការបង្ហាញ ឬការកែសម្រួលក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន:

- លោក Michael John Spingler — ប្រធានក្រុមប្រឹក្សាភិបាល
- លោកស្រី Fernanda Pecanha Lacerda De Lima — នាយក
- លោក Ry Vanna — នាយក (លាឈប់នៅថ្ងៃទី10 ខែ មេសា ឆ្នាំ 2011)
- លោក Chandula P.Abeywickrema — នាយក (តែងតាំងនៅថ្ងៃទី17 ខែ កញ្ញា ឆ្នាំ 2010)

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកណាម្នាក់កាន់កាប់ ឬមានជាប់ទាក់ទិនផ្ទាល់នៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុននោះទេ ។ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាគូភាគីក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុន ពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតទេ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងនិងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុន ឬលិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធមួយ ជាមួយនឹងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 និងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពចលនាសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទឆ្នាំដែលបានបញ្ចប់ ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវៈ

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របដោយផ្អែកលើការវិនិច្ឆ័យនិងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍ឲ្យបានជាប់លាប់ ។

(ខ) អនុវត្តទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធ នឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវគឺត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាព ។

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថាក្រុមហ៊ុន នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត ដែលគិតទុកជាមុន និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសម្រេច ដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលៈ

Michael Spingler

លោក **Michael John Spingler**

*ប្រធានក្រុមប្រឹក្សាភិបាល*

ថ្ងៃទី 29 APR 2011

KPMG Cambodia Ltd
4th floor, Delano Center
No. 144, Street 169
Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia

Telephone +855 (23) 216 899
Fax +855 (23) 217 279
Internet www.kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះម្ចាស់ភាគហ៊ុន
## ធនាគារភូមិ (ខេមបូឌា) អិលធីឌី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ធនាគារភូមិ (ខេមបូឌា) អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 និងរបាយការណ៍លទ្ធផលរួម របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន និងរបាយការណ៍ចលនាសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សំគាល់ដែលរួមមាន សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗដែលបានបង្ហាញនៅទំព័រទី 7 ដល់ទី 50 ។ តួលេខប្រៀបធៀបដែលបានបង្ហាញ គឺផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 ដែលបានធ្វើសវនកម្ម ដោយក្រុមហ៊ុនសវនកម្មផ្សេងទៀត ដែលក្នុងរបាយការណ៍របស់ខ្លួន ចុះថ្ងៃទី 27 ខែ មេសា ឆ្នាំ 2010 បានបញ្ចេញមតិថារបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិត និងត្រឹមត្រូវ ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីកំហុសឆ្គងជាសារវ័ន្ត ដោយសារតែការក្លែងបន្លំ ឬការភាន់ច្រឡំ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺការបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ស្តង់ដារទាំងនេះ តម្រូវឲ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ ដោយគ្រោង និងធ្វើសវនកម្មដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវ័ន្តឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តន៍នូវបណ្តានិតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់ និងកំណត់បង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនិតិវិធីទាំងនេះ គឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំ ដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យ ដែលមានផលប៉ះពាល់ជាសារវ័ន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធ្វើសវនកម្មឲ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់ទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។



2010 KPMG Cambodia Ltd., a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity. All rights reserved.

ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានសំខាន់ៗ ដែលធ្វើឡើងដោយគណៈគ្រប់គ្រងព្រមទាំងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## មតិយោបល់

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ធនាគារភូមិ (ខេមបូឌា) អិលធីឌី** នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 ព្រមទាំងលទ្ធផលប្រតិបត្តិការអាជីវកម្ម និងស្ថានភាពចលនាសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយស្របទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

**តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់**

Craig McDonald
*Audit Partner*

រាជធានីភ្នំពេញ

ថ្ងៃទី 29 ខែ មេសា ឆ្នាំ 2011

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | កំណត់សំគាល់ | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 322,678 | 226,913 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | 6 | 34,946,852 | 44,806,732 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 7 | 215,200 | 215,200 |
| ឥណទានផ្តល់ដល់អតិថិជន | 8 | 88,459,910 | 68,873,899 |
| គណនីត្រូវទទួលផ្សេងៗ | 9 | 2,364,604 | 1,708,692 |
| អចលនទ្រព្យ និងទ្រព្យសម្ភារ | 10 | 1,199,820 | 1,022,955 |
| ទ្រព្យសកម្មអរូបិយ | 11 | 14,819 | 29,638 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 12 | 139,639 | 183,937 |
| **ទ្រព្យសកម្មសរុប** | | 127,663,522 | 117,067,966 |
| **ទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន** | | | |
| **ទ្រព្យអកម្ម** | | | |
| ប្រាក់បញ្ញើពីអតិថិជន | 13 | 394,981 | 422,592 |
| ប្រាក់កម្ចី | 14 | 99,081,495 | 93,053,692 |
| គណនីត្រូវទូទាត់ផ្សេងៗ | 15 | 2,705,933 | 2,057,940 |
| ជំនួយពន្យារ | | 16,298 | 21,731 |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវទូទាត់ | 12 | 618,069 | 155,132 |
| **ទ្រព្យអកម្មសរុប** | | 102,816,776 | 95,711,087 |
| **មូលនិធិម្ចាស់ហ៊ុន** | | | |
| ដើមទុន | 16 | 4,000,000 | 4,000,000 |
| ទុនបំរុង | | 1,373,211 | 788,740 |
| ប្រាក់ចំណេញរក្សាទុក | | 19,473,535 | 16,568,139 |
| មូលនិធិម្ចាស់ហ៊ុនសរុប | | 24,846,746 | 21,356,879 |
| **ទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុនសរុប** | | 127,663,522 | 117,067,966 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍លទ្ធផលរួម
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | កំណត់សំគាល់ | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|---|
| ចំណូលការប្រាក់ | 17 | 26,546,534 | 25,847,339 |
| ចំណាយការប្រាក់ | 18 | (9,396,460) | (9,951,100) |
| **ចំណូលការប្រាក់សុទ្ធ** | | 17,150,074 | 15,896,239 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 19 | 326,587 | 260,103 |
| **ចំណូលប្រតិបត្តិការ** | | 17,476,661 | 16,156,342 |
| កំរៃជើងសារ | 20 | (475,559) | (782,326) |
| ចំណាយបុគ្គលិក | 21 | (8,665,513) | (6,005,982) |
| ចំណាយរំលស់ | | (591,344) | (492,872) |
| ចំណាយរដ្ឋបាល | 22 | (3,736,556) | (2,533,144) |
| សំវិធានធនសម្រាប់ឥណទាន អាក្រក់ និងជាប់សង្ស័យ | | 378,277 | (4,187,052) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | | 4,385,966 | 2,154,966 |
| ចំណូលបានពីជំនួយ | | 10,328 | 7,244 |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | 4,396,294 | 2,162,210 |
| ពន្ធលើប្រាក់ចំណេញ | 12 | (906,427) | (438,926) |
| **ចំណេញសុទ្ធ/ចំណូលរួមសម្រាប់ការិយបរិច្ឆេទ** | | 3,489,867 | 1,723,284 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | ដើមទុន<br>ពាន់រៀល | ទុនបំរុង<br>ពាន់រៀល | ប្រាក់ចំណេញ<br>រក្សាទុក<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|
| សមតុល្យនាថ្ងៃទី1 ខែ មករា ឆ្នាំ 2009 | 4,000,000 | 788,740 | 14,844,855 | 19,633,595 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 1,723,284 | 1,723,284 |
| សមតុល្យនាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2009 | 4,000,000 | 788,740 | 16,568,139 | 21,356,879 |
| ផ្ទេរប្រាក់ចំណេញរក្សាទុកទៅទុនបំរុង | - | 584,471 | (584,471) | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 3,489,867 | 3,489,867 |
| សមតុល្យនាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2010 | 4,000,000 | 1,373,211 | 19,473,535 | 24,846,746 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍ចលនាសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | |
| ប្រាក់ចំណេញមុនបង់ពន្ធ | 4,396,294 | 2,162,210 |
| និយ័តកម្មលើចំណូលនិងចំណាយមិនមែនសាច់ប្រាក់: | | |
| រំលស់ | 591,344 | 492,872 |
| ប្រាក់ជំនួយ | (10,328) | (7,244) |
| (ដកចេញ)/សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | (378,277) | 4,187,052 |
| ខាតពីការលក់អចលនទ្រព្យ និងទ្រព្យសម្ភារ | - | 12,979 |
| | 4,599,033 | 6,847,869 |
| ការប្រែប្រួលនៃ: | | |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | 3,280,236 | (823,907) |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | - | (10,000) |
| ឥណទានផ្តល់ដល់អតិថិជន | (19,207,734) | 1,630,374 |
| គណនីត្រូវទទួលផ្សេងៗ | (655,912) | 155,583 |
| ប្រាក់បញ្ញើពីអតិថិជន | (27,611) | 95,081 |
| គណនីត្រូវទូទាត់ផ្សេងៗ | 647,993 | 59,213 |
| សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (11,363,995) | 7,954,213 |
| ពន្ធលើប្រាក់ចំណេញបានបង់ | (399,192) | (1,204,659) |
| ប្រាក់ជំនួយទទួលបាន | 4,895 | - |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (11,758,292) | 6,749,554 |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | |
| ការទិញទ្រព្យអចនលទ្រព្យ និងសម្ភារ | (753,390) | (176,985) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (753,390) | (176,985) |

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍ចលនាសាច់ប្រាក់ (ត)
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 71,142,366 | 74,726,930 |
| ការទូទាត់សងប្រាក់កម្ចី | (65,114,563) | (73,306,592) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | 6,027,803 | 1,420,338 |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (6,483,879) | 7,992,907 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | 24,784,178 | 16,791,271 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 18,300,299 | 24,784,178 |

| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន:** | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ-(កំណត់សំគាល់5) | 322,678 | 226,913 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅ ធនាគារនានា(មានកាលកំណត់ 3 ខែ ឬតិចជាង (កំណត់សំគាល់ 6) | 17,977,621 | 24,557,265 |
| | 18,300,299 | 24,784,178 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

## 1. អង្គភាពរាយការណ៍

**ធនាគារភូមិ (ខេមបូឌា) អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលមានអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុត្រូវបានបង្កើតឡើងជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត ក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី 23 ខែ ឧសភា ឆ្នាំ 2002 ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ Co. 1413/02E ដែលចេញដោយក្រសួងពាណិជ្ជកម្ម ។

ក្រុមហ៊ុន ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបាននិងកំពុងបន្តសកម្មភាពចំបងជាស្ថាប័នផ្តល់ឥណទានដល់ប្រជាជននៅតាមជនបទក្នុង 27 តំបន់ ដែលមានសាខាចំបងចំនួន 11 និងស្នាក់ការកណ្តាលនៅភ្នំពេញ ។ គោលដៅរបស់ក្រុមហ៊ុន គឺផ្តល់នូវសេវាមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងអាច លៃលកបាន ដល់សហគ្រិនខ្នាតតូចនៅតាមជនបទ និងបរិវេណជុំវិញទីក្រុងភ្នំពេញ ។

ក្នុងបណ្តាខេត្តក្រុងចំនួន 24 នៅក្នុងប្រទេសកម្ពុជា ធនាគារភូមិ មានប្រតិបត្តិការនៅ 16 ខេត្តមានដូចជា បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ក្រចេះ កែប ឧត្តរមានជ័យ ភ្នំពេញ ព្រៃវែង សៀមរាប ស្វាយរៀង និងតាកែវ ។ សេវាកម្មហិរញ្ញវត្ថុផ្តល់តាមរយៈធនាគារតាមភូមិ ដែលបង្កើតឡើងដោយក្រុមសាមគ្គីដែលមានសមាជិករហូតដល់ 5 នាក់ ក្នុង មួយក្រុម ឬក្រុមសាមគ្គីនិមួយៗ ។

ក្រុមហ៊ុនបានទទួលនូវអាជ្ញាប័ណ្ណរយៈពេល៣ឆ្នាំ ដើម្បីធ្វើអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2003 ដល់ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2006 ពីធនាគារជាតិនៃកម្ពុជា។ នៅថ្ងៃទី 20 ខែ មករា 2006 ធនាគារជាតិនៃកម្ពុជាបានបន្តអាជ្ញាប័ណ្ណនេះសម្រាប់រយៈពេល 3 ឆ្នាំទៀតចាប់ពី ថ្ងៃទី 12 ខែកុម្ភៈ 2006 ដល់ថ្ងៃទី 12 ខែកុម្ភៈ 2009 ។ នៅថ្ងៃទី14 ខែមករា 2009 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណជាអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា ។

ទីស្នាក់ការចុះបញ្ជីមានទីតាំងនៅផ្ទះលេខ 94 ផ្លូវ 360 សង្កាត់បឹងកេងកង 3 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

## 2. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងជាលើកទីមួយស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានអនុញ្ញាតនិងសម្រេចអនុម័តដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី 29 ខែ មេសា ឆ្នាំ 2011 ។

### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងតាមមូលដ្ឋានតម្លៃដើម ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 2. មូលដ្ឋាននៃការរៀបចំ (ត)

#### (គ) រូបិយប័ណ្ណសម្រាប់វាស់វែង និងសម្រាប់បង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានបីរូបិយប័ណ្ណ គឺប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ ។ គណៈគ្រប់គ្រង បានកំណត់ប្រាក់រៀលជារូបិយប័ណ្ណសម្រាប់វាស់វែងនិងសម្រាប់កំណត់បង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ដោយប្រតិបត្តិការផ្តល់ឥណទានភាគច្រើនធ្វើឡើងជាប្រាក់រៀល ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ ទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុដែលជារូបិយប័ណ្ណផ្សេងទៀតក្រៅពីប្រាក់រៀលត្រូវបានប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទរាយការណ៍ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណ ដែលកើតមកពីការប្តូរនោះត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។

#### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឲ្យស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មត ដែលប៉ះពាល់ដល់ការអនុវត្តន៍នូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម ទ្រព្យអកម្ម ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែង អាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើគណនីប៉ាន់ស្មានត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាននោះ ត្រូវបានត្រួតពិនិត្យឡើងវិញ និងនៅក្នុងការិយបរិច្ឆេទដែលផលប៉ះពាល់នោះនឹងកើតមានឡើងនាពេលអនាគត ។

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ

#### (ក) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ និងសមតុល្យធនាគារ ប្រាក់បញ្ញើនៅធនាគារ និងការវិនិយោគរយៈពេលខ្លីដែលអាចប្តូរជាសាច់ប្រាក់បានក្នុងរយៈពេល 3 ខែ ឬតិចជាងនេះនៅពេលទិញ ហើយដែលអាចប្តូរជាសាច់ប្រាក់បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ខ) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានកត់ត្រាតាមថ្លៃដើមដែលនៅសល់ដកចំនួនដែលបានលុបចោលសំវិធានធនជាក់លាក់ និងសំវិធានធនទូទៅ ។

#### (គ) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុលោមទៅតាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនជាក់លាក់ចំពោះឥណទានអាក្រក់ និងជាប់សង្ស័យត្រូវបានធ្វើតែទៅលើឥណទានដែលបានចាត់ទុកថាមិនដំណើរការ ដែលត្រូវធ្វើឡើងដូចខាងក្រោម:

| **ចំណាត់ថ្នាក់** | **ចំនួនថ្ងៃដែលហួសកាលកំណត់សង** | **អត្រាសំវិធានធន** |
|---|---|---|
| *ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ):* | | |
| ឥណទានក្រោមស្តង់ដារ | ពី 30 ទៅ 59 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 60 ទៅ 89 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | លើសពី 90 ថ្ងៃ | 100% |
| *ឥណទានរយៈពេលវែង (លើសពីមួយឆ្នាំ):* | | |
| ឥណទានក្រោមស្តង់ដារ | ពី 30 ទៅ 179 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 180 ទៅ 359 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | លើសពី 360 ថ្ងៃ | 100% |

សំវិធានធនជាក់លាក់ ត្រូវបានគណនាតាមភាគរយនៃឥណទានមិនទាន់សងនាចុងការិយបរិច្ឆេទ ហើយត្រូវបានកត់ត្រាជាចំណាយក្នុងចំណេញ ឬខាត ។

ក្រុមហ៊ុនកត់ត្រាសំវិធានធន 100% សម្រាប់ឥណទានដែលហួសកាលកំណត់សងលើសពី 30 ថ្ងៃ ។ ចំនួនសំវិធានធនដែលលើសកំរិតតម្រូវដោយធនាគារជាតិកម្ពុជា ត្រូវបានបង្ហាញជាសំវិធានធនទូទៅ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យត្រូវបានវាយតម្លៃដោយគណៈគ្រប់គ្រងជារៀងរាល់ខែ ។ លក្ខខណ្ឌទាំងឡាយត្រូវបានពិចារណាក្នុងការវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចជា ទំហំនៃឥណទានបទពិសោធន៍នៃការខាតបង់កន្លងទៅ លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងស្ថានភាពជាក់ស្តែងនៃឥណទានធៀបនឹងដំណើរការនៃឥណទានក្នុងកំឡុងពេលនៃកិច្ចសន្យា ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (គ) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ (ត)

ឥណទាន ត្រូវបានលុបបំបាត់ចោល បន្ទាប់ពីគណៈគ្រប់គ្រងវិនិច្ឆ័យឃើញថាពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះមកវិញទេ ។ ឥណទានដែលបានលុបចោល ត្រូវបានកាត់ចេញពីឥណទានដែលនៅសល់និងពីសំវិធានធនសម្រាប់ឥណទានបាត់បង់ ។

ការប្រមូលបានមកវិញនូវឥណទានដែលបានលុបបំបាត់ចោលពីពេលមុន ត្រូវបានកត់ជាចំណូលប្រតិបត្តិការផ្សេងៗក្នុងចំណេញ ឬខាត ។

#### (ង) ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ។

#### (ជ) ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ក្រុមហ៊ុន និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

#### (ឈ) គណនីត្រូវទទួលផ្សេងៗ

គណនីត្រូវទទួលផ្សេងៗ ត្រូវបានកត់ត្រាដំបូងតាមតម្លៃទីផ្សារ បូកបន្ថែមនូវថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធដោយផ្ទាល់ ។ នៅពេលដែលឥណទានត្រូវបានពន្យាលើសពីលក្ខខណ្ឌធម្មតា គណនីត្រូវទទួលត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើអត្រាការប្រាក់ប្រសិទ្ធិភាព ។

នៅរៀងរាល់ចុងកាលបរិច្ឆេទរាយការណ៍ តម្លៃយោងរបស់គណនីត្រូវទទួល ត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថា តម្លៃយោងនោះមិនអាចប្រមូលមកវិញបាន ។ បើសិនដូច្នេះ ការខាតបង់លើឱនភាពតម្លៃ ត្រូវទទួលស្គាល់ភ្លាមៗនៅក្នុងចំណេញ ឬខាត ។

#### (ញ) អចលនទ្រព្យ និងទ្រព្យសម្ភារ

*(i) ការទទួលស្គាល់ និងការវាស់វែង*

អចលនទ្រព្យ និងទ្រព្យសម្ភារ ត្រូវបានកត់ត្រាតាមតម្លៃដើមដករំលស់បង្គរ និងឱនភាពតម្លៃបង្គរប្រសិនបើមាន ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ញ) អចលនទ្រព្យ និងទ្រព្យសម្ភារ (ត)

នៅពេលដែលធាតុរបស់អចលនទ្រព្យ និងទ្រព្យសម្ភារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះ ត្រូវបានចាត់ទុកជាធាតុផ្សេងគ្នា (ធាតុសំខាន់ៗ) របស់អចលនទ្រព្យ និងទ្រព្យសម្ភារ ។

ចំណេញ ឬខាតពីការបោះចោល ឬការលក់ចេញនូវអចលនទ្រព្យ និងទ្រព្យសម្ភារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងរបស់អចលនទ្រព្យ និងទ្រព្យសម្ភារនោះ ហើយត្រូវបានទទួលស្គាល់ជាចំណូលផ្សេងៗ នៅក្នុងចំណេញ ឬខាត ។

*(ii) ការចំណាយបន្ទាប់*

ចំណាយក្នុងការជំនួសធាតុណាមួយរបស់អចលនទ្រព្យ និងទ្រព្យសម្ភារ ត្រូវបានកត់ត្រាតាមតម្លៃយោងរបស់ធាតុនោះ នៅពេលដែលធាតុនោះមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុន ហើយចំណាយនោះអាចវាស់វែងដែលអាចជឿជាក់បាន ។ តម្លៃយោងរបស់ធាតុដែលត្រូវបានជំនួស ត្រូវបានបានដកចេញ ។ ថ្លៃសេវាប្រចាំថ្ងៃលើអចលនទ្រព្យ និងទ្រព្យសម្ភារ ត្រូវកត់ត្រានៅក្នុងចំណេញ ឬខាត នៅពេលដែលថ្លៃសេវានោះកើតឡើង ។

*(iii) រំលស់*

រំលស់ត្រូវបានគណនាដោយផ្អែកលើចំនួនដែលអាចដករំលស់បាន ដែលជាថ្លៃដើមរបស់អចលនទ្រព្យ ឬក៏ចំនួនផ្សេងទៀតដែលចាត់ទុកជាថ្លៃដើម ហើយដកចេញនូវតម្លៃដែលនៅសល់ ។

រំលស់ ត្រូវបានបញ្ចូលជាចំណាយនៅក្នុងចំណេញ ឬខាត ផ្អែកលើមូលដ្ឋានរំលស់ថយចុះជាលំដាប់ ដោយប្រើតម្លៃយោងនៃទ្រព្យសកម្មនីមួយៗនាដើមការិយបរិច្ឆេទផ្អែកតាមអត្រាដូចខាងក្រោម:

| | |
|---|---|
| គ្រឿងសង្ហារឹមនិងសម្ភារការិយាល័យ | 25% |
| យានយន្ត | 25% |
| កុំព្យូទ័រ | 50% |

ប្រសិនបើមានការគូសបញ្ជាក់ណាមួយឲ្យដឹងថា មានការផ្លាស់ប្តូរជាសារវ័ន្តនូវអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់របស់អចលនទ្រព្យ រំលស់អចលនទ្រព្យនោះត្រូវកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ដ) ទ្រព្យសកម្មអរូបិយ

ទ្រព្យសកម្មអរូបិយ ដែលរួមមានកុំព្យូទ័រសូហ្វវែរ ត្រូវបានកំណត់ដោយតម្លៃដើមដករំលោះបង្គរ និងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន ។ រំលស់ ត្រូវបានគណនាផ្អែកលើមូលដ្ឋានរំលស់ថយចុះជាលំដាប់ផ្អែកតាមអត្រា 50% ក្នុងមួយឆ្នាំ ។ ប្រសិនបើមានការគូសបញ្ជាក់ណាមួយឲ្យដឹងថាមានការផ្លាស់ប្តូរជាសារវន្តនូវអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់របស់ទ្រព្យសកម្មអរូបិយ រំលស់ទ្រព្យសកម្មអរូបិយនោះត្រូវកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី ។

### (ឋ) ឱនភាពនៃតម្លៃ

តម្លៃយោងនៃអចលនទ្រព្យ និងទ្រព្យសម្ភារ និងទ្រព្យសកម្មអរូបិយត្រូវបានត្រួតពិនិត្យនៅរាល់កាលរាយការណ៍ ដើម្បីកំណត់ថាតើមានកត្តាដែលដែលនាំឲ្យមានការខាតបង់លើឱនភាពឬទេ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើង ការប៉ាន់ស្មានតម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង ។

ប្រសិនបើការប៉ាន់ស្មាននូវតម្លៃដែលអាចទទួលបានមកវិញតិចជាងតម្លៃយោង វាត្រូវបានកាត់បន្ថយមកនៅត្រឹមតម្លៃប៉ាន់ស្មានដែលអាចទទួលបានមកវិញ ហើយការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងចំណេញឬខាត ។

ប្រសិនបើការខាតបង់លើឱនភាពនៃតម្លៃត្រូវបានកាត់បន្ថយ តម្លៃយោងនៃទ្រព្យសកម្ម (ឬក្រុមទ្រព្យដែលពាក់ព័ន្ធ) ត្រូវបានបញ្ចូលមកវិញត្រឹមតម្លៃយោង (តម្លៃលក់ដកថ្លៃក្នុងការលក់ចេញករណីសន្និធិ) ប៉ុន្តែធ្វើយ៉ាងណាមិនលើសតម្លៃយោងដែលបានកំណត់ថាគ្មានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្ម (ឬក្រុមទ្រព្យដែលពាក់ព័ន្ធ) ក្នុងឆ្នាំមុន។ ការខាតបង់លើឱនភាពតម្លៃ ត្រូវបានកត់ត្រានៅក្នុងចំណេញ ឬខាត។

### (ឌ) ប្រាក់បញ្ញើរបស់អតិថិជន

ប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានកត់ត្រាតាមតម្លៃនៃប្រាក់តម្កល់ ។

### (ឍ) ប្រាក់កម្ចី

ប្រាក់កម្ចី ត្រូវបានកត់ត្រាដំបូងតាមតម្លៃទីផ្សារ (ជាតម្លៃបច្ចុប្បន្នរបស់សាច់ប្រាក់ត្រូវទូទាត់ទៅឲ្យម្ចាស់បំណុល រួមទាំងថ្លៃដើមប្រតិបត្តិការ) ។ បន្ទាប់ពីការកត់ត្រាដំបូងរួច ប្រាក់កម្ចីត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ។ រាល់ចំណាយទាំងអស់ទាក់ទងនឹងប្រាក់កម្ចី ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត នៅក្នុងការិយបរិច្ឆេទដែលចំណាយទាំងនោះកើតឡើង ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) គណនីត្រូវទូទាត់ផ្សេងៗ

គណនីត្រូវទូទាត់ផ្សេងៗត្រូវបានកត់ត្រាដំបូងតាមតម្លៃទីផ្សារ បូកបន្ថែមនូវថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធដោយផ្ទាល់ ។ បន្ទាប់ពីការកត់ត្រាដំបូងរួច គណនីនេះត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើអត្រាការប្រាក់ប្រសិទ្ធិភាព លើកលែងតែគណនីត្រូវទូទាត់ដែលពុំមានការប្រាក់ហើយដែលផ្អែកលើលក្ខខណ្ឌឥណទានធម្មតា គឺមិនត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមនោះទេ ។

### (ត) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ឬកិច្ចសន្យាដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន និងអាចមានលទ្ធភាព ដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចដើម្បីបំពេញនូវកាតព្វកិច្ចនោះ ។ សំវិធានធន ត្រូវបានកំណត់ដោយការបញ្ចុះតម្លៃសាច់ប្រាក់ដែលរំពឹងថានឹងទទួលបាននាពេលអនាគត មកនៅត្រឹមតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់មុនដកពន្ធ ដែលអត្រានេះឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្នរបស់តម្លៃពេលវេលា និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យអកម្មនោះ ។ ការបញ្ចុះតម្លៃនេះ ត្រូវបានចាត់ជាថ្លៃដើមហិរញ្ញវត្ថុ ។

### (ថ) ទុនបំរុង

ទុនបំរុង តំណាងឱ្យប្រាក់ចំណេញដែលបានផ្ទេរពីកម្មវិធីធនាគារភូមិ ។ ប្រាក់ចំណេញសុទ្ធចំនួន 5% បន្ទាប់ពីការដកការខាតបង់ពីគ្រាមុន ត្រូវបានផ្ទេរទៅទុនបំរុង ។ ការផ្ទេរនេះនឹងផ្អាកនៅពេលទុនបំរុងស្មើនឹង 10% នៃដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុន ។ ទុនបំរុងនេះក៏រួមបញ្ចូលការផ្ទេរប្រាក់ចំណេញរក្សាទុកចំនួន 3.5% នៃប្រាក់កម្ចីមិនទាន់ទូទាត់សងឲ្យ Instituto de Credito Oficial ("ICO")។

### (ទ) សម្ព័ន្ធញាតិ

ភាគី ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិរបស់ក្រុមហ៊ុន ប្រសិនបើភាគីមួយមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើភាគីមួយទៀត ឬមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាគីនោះក្នុងការធ្វើសេចក្តីសម្រេចលើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬប្រសិនបើក្រុមហ៊ុន និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលយ៉ាងខ្លាំង ។ សម្ព័ន្ធញាតិ អាចជារូបវន្តបុគ្គល ឬនីតិបុគ្គល និងរួមបញ្ចូលនូវសមាជិកគ្រួសារដែលជិតស្និទ្ធរបស់រូបវន្តបុគ្គលណាម្នាក់ដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ទ) សម្ព័ន្ធញាតិ (ត)

នៅក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និយមន័យរបស់សម្ព័ន្ធញាតិរួមបញ្ចូលផងដែរនូវភាគីដែលកាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលយ៉ាងតិច 10% នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត ហើយរាប់បញ្ចូលនូវរូបវន្តបុគ្គលណាដែលរួមចំណែកក្នុងការអភិបាល ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន ។

### (ធ) ការទទួលស្គាល់ប្រាក់ចំណូល និងចំណាយ

ចំណូលការប្រាក់លើឥណទាន ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានមួយក្លាយជាឥណទានមិនដំណើរការ ការកត់ត្រាការប្រាក់ថាជាចំណូលត្រូវបានព្យួរទុក ហើយត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់ ។ ចំណូលការប្រាក់ ត្រូវបានធ្វើការគណនារៀងរាល់ខែ ដោយផ្អែកលើប្រាក់ដើមដែលនៅសល់ពីខែមុន ។

ចំណាយត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ។

### (ន) ជំនួយ

ជំនួយដែលទទួលបាន ដើម្បីជួយទៅលើប្រតិបត្តិការទាំងឡាយរបស់ក្រុមហ៊ុនត្រូវបានបញ្ចូលទៅក្នុងចំណេញ ឬខាតផ្អែកតាមមូលដ្ឋានជាប្រព័ន្ធ និងសមស្របដោយផ្គូរផ្គងជាមួយនឹងចំណាយដែលត្រូវទូទាត់ ។

ជំនួយដែលទទួលបានសម្រាប់ការទិញអចលនទ្រព្យ និងទ្រព្យសម្ភារត្រូវបានបញ្ចូលទៅក្នុងចំណេញ ឬខាតផ្អែកតាមមូលដ្ឋានជាប្រព័ន្ធទៅតាមអាយុកាលនៃការប្រើប្រាស់របស់ទ្រព្យសកម្ម ។ ជំនួយដែលមិនទាន់បានបញ្ចូលទៅក្នុងចំណេញ ឬខាតត្រូវបានបង្ហាញជាជំនួយពន្យារ។

### (ប) ភតិសន្យាប្រតិបត្តិ

ថ្លៃឈ្នួលដែលបានបង់លើភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតតាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃការជួល ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ផ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតលើកលែងតែក្នុងករណីដែលពន្ធនោះទាក់ទងទៅនឹងសមាសធាតុ ដែលបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងរបាយការណ៍មូលនិធិម្ចាស់ហ៊ុន ឬ ក្នុងចំណូលរួមផ្សេងៗ ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលនឹងត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធក្នុងការិយបរិច្ឆេទ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានកំណត់ជាអាទិ៍នៅថ្ងៃធ្វើរបាយការណ៍ ជាមួយនឹងនិយ័តកម្មណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកំណត់ទៅលើភាពលំអៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលប្រើក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃដែលប្រើក្នុងគោលបំណងនៃការគិតពន្ធ (ហៅថាភាពលំអៀងបណ្តោះអាសន្ន) ។ ពន្ធពន្យារជាទ្រព្យអកម្ម ត្រូវបានទទួលស្គាល់ចំពោះភាពលំអៀងបណ្តោះអាសន្នទាំងឡាយណា ដែលអាចនាំឲ្យកើតមានឡើងនូវប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ចំពោះភាពលំអៀងបណ្តោះអាសន្នទាំងឡាយណា ដែលអាចនាំឲ្យមានការថយចុះនូវប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ការខាតពន្ធមិនទាន់បានប្រើ និងឥណទានពន្ធមិនទាន់បានប្រើ ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានវាស់វែងតាមចំនួនដែលគិតថាអាចប្រមូលមកវិញបាន ដោយផ្អែកលើមូលដ្ឋានប្រាក់ចំណេញជាប់ពន្ធនាពេលបច្ចុប្បន្ន និងពេលអនាគត ។

តម្លៃយោងសុទ្ធរបស់ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ។ រាល់និយ័តកម្មទាំងអស់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

ពន្ធពន្យារត្រូវបានគណនាតាមអត្រាពន្ធ ដែលប្រើសម្រាប់ប្រាក់ចំណេញជាប់ពន្ធ (ការខាតពន្ធ) ក្នុងការិយបរិច្ឆេទ ដែលពន្ធពន្យារជាទ្រព្យសកម្មអាចនឹងទទួលបាន ឬពន្ធពន្យារជាទ្រព្យអកម្មអាចនឹងត្រូវទូទាត់ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានកំណត់ជាអាទិ៍នាកាលបរិច្ឆេទរាយការណ៍ ។

## 4. ការផ្លាស់ប្តូរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់កាលបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 គឺជារបាយការណ៍ទីមួយ ដែលត្រូវបានរៀបចំឡើងដោយប្រើគោលនយោបាយគណនេយ្យដែលអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម ។

កាលបរិច្ឆេទនៃការផ្លាស់ប្តូរនេះ គឺនៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2009 ដែលជាថ្ងៃក្រុមហ៊ុនបានរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដំបូងទៅតាមស្តង់ដារនេះ ។

ការផ្លាស់ប្តូរពីស្តង់ដារគណនេយ្យកម្ពុជា ទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម មិនមានផលប៉ះពាល់ជាសារវន្តទៅលើស្ថានភាពហិរញ្ញវត្ថុ លទ្ធផលអាជីវកម្ម និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនដែលបានរាយការណ៍ឡើយ ។

## 5. សាច់ប្រាក់ក្នុងដៃ

| | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| ទីស្នាក់ការកណ្តាល | 2,000 | 2,000 |
| សាខានានា | 320,678 | 224,913 |
| | 322,678 | 226,913 |

សាច់ប្រាក់ក្នុងដៃ ត្រូវបានធ្វើការវិភាគបន្ថែមដូចខាងក្រោម:

| | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| ប្រាក់រៀល | 182,654 | 181,648 |
| ប្រាក់ដុល្លារអាមេរិក | 130,798 | 30,092 |
| ប្រាក់បាតថៃ | 9,226 | 15,173 |
| | 322,678 | 226,913 |

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

### 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

| | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| ប្រាក់បញ្ញើចរន្ត | | |
| ធនាគារជាតិនៃកម្ពុជា | 42,194 | 130,620 |
| ធនាគារអេស៊ីលីដា | 8,523,806 | 4,221 |
| ប្រាក់បញ្ញើសន្សំ | | |
| ធនាគារអេស៊ីលីដា | 1,990,429 | 8,717,543 |
| ធនាគារអភិវឌ្ឍជនបទនៃកម្ពុជា | 588 | 634 |
| ប្រាក់បញ្ញើមានកាលកំណត់ | | |
| ធនាគារជាតិនៃកម្ពុជា | 6,606,390 | 16,175,720 |
| ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 17,783,445 | 19,777,994 |
| | 34,946,852 | 44,806,732 |

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានធ្វើការវិភាគបន្ថែម ដូចខាងក្រោម:

(ក) តាមកាលកំណត់:

| | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| រយៈពេល 1 ខែ | 10,557,017 | 10,937,517 |
| 2 ទៅ 3 ខែ | 7,420,604 | 13,619,748 |
| 3 ទៅ 4 ខែ | 16,969,231 | 20,249,467 |
| | 34,946,852 | 44,806,732 |

(ខ) តាមរូបិយប័ណ្ណ:

| | | |
|---|---|---|
| ប្រាក់រៀល | 1,398,375 | 7,931,499 |
| ប្រាក់ដុល្លារអាមេរិក | 33,096,412 | 36,561,061 |
| ប្រាក់បាតថៃ | 452,065 | 314,172 |
| | 34,946,852 | 44,806,732 |

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

## 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា (ត)

(គ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)

| | 2010 | 2009 |
|---|---|---|
| ធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា | 0.05% - 4.00% | 0.10% - 4.00% |

## 7. ប្រាក់បញ្ញើតម្កល់តាមច្បាប់

| | 2010<br>ពាន់រៀល | 2009<br>ពាន់រៀល |
|---|---|---|
| ប្រាក់បញ្ញើតម្កល់តាមច្បាប់លើ: | | |
| ដើមទុនចុះបញ្ជី | 200,000 | 200,000 |
| ប្រាក់បញ្ញើរបស់អតិថិជន | 15,200 | 15,200 |
| | 215,200 | 215,200 |

